វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៥៧ អនក្រ/ថ្ងៃទី ២៩ ខែកញ្ញា ១៩៩៤

អនុក្រឹត្យស្តីពី ការផ្តល់សិទ្ធិចុះហត្ថលេខាលើប្លង់ដីកម្មសិទ្ធិ ការផ្ទេរកម្មសិទ្ធិ និងអាជ្ញាប័ណ្ណសាងសង់អគារ ក្នុងរាជធានីភ្នំពេញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសេចក្តីត្រូវការចាំបាច់

សំរេច

មាត្រា ១

ឯកឧត្តម ប្រតិភូរាជរដ្ឋាភិបាល ប្រចាំរាជធានីភ្នំពេញ ជាអ្នកមានសិទ្ធិចុះហត្ថលេខាលើប្លង់ដីកម្មសិទ្ធិ ការផ្ទេរកម្មសិទ្ធិ និងអាជ្ញាប័ណ្ណសាងសង់អគារគ្រប់ផ្នែក ក្នុងរាជធានីភ្នំពេញ ។

មាត្រា ២

ក្នុងករណីអវត្តមាន ឯកឧត្តមប្រតិភូ ត្រូវផ្ទេរសិទ្ធិជូនអភិបាលរងម្នាក់ ដើម្បីចុះហត្ថលេខាជំនួស ។

មាត្រា ៣

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី និង រដ្ឋលេខាធិការនៃក្រសួងស្ថាប័នពាក់ព័ន្ធ និង ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ត្រូវទទួលអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហត្ថលេខា និង ចុះហត្ថលេខាតទៅ ។